**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងរដ្ឋប្បវេណីលេខ: ៦២
ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២៤
សាលក្រមរដ្ឋប្បវេណីលេខ: ៣០ "ក"
ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៤

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តតាកែវ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៤ នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រម**

លោកជំទាវ [redacted] ប្រធានសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**អត្តសញ្ញាណភាគី:**

-ដើមចោទ [redacted] (ខេមបូឌា) ម.ក មានអាសយដ្ឋានចុះបញ្ជីនៅ [redacted] ព្រះរាជាណាចក្រកម្ពុជា ដែលមានអ្នកតំណាងស្របច្បាប់ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៨៩ មានតួនាទីជា អ្នកត្រួតពិនិត្យផ្នែកច្បាប់ ។

លោកស្រី [redacted] អត្តលេខ:២៦១៧ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ។

-សហចុងចម្លើយឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ ៥២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ៖ ១០០៧៧១៩៨២ និង ប្រពន្ធឈ្មោះ [redacted] ស៊ីវឡេង ភេទស្រី អាយុ ៥០ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ៖១០០៧៧១៩៨០ មានអាសយដ្ឋានស្ថិតនៅភូមិ [redacted] ។

មេធាវីតំណាងដោយអាណត្តិ លោក [redacted] ពុទ្ធិរិទ្ធ អត្តលេខ: ២៨៣៣ T និង លោក [redacted] ច័ន្ទតារា អត្តលេខ: ២៨៤៥ T ។

**អង្គហេតុ និង ចំណុចវិវាទ**

ក.ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ:

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] វុត្ថា និងឈ្មោះ [redacted] ស៊ីវឡេង រួមគ្នាសង ដោយកាតព្វកិច្ចសាមគ្គីទៅឱ្យដើមចោទ [redacted] ម.ក នូវទឹកប្រាក់នៅជំពាក់ដូចខាងក្រោម៖

១.១-ប្រាក់ដើមនៅជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន ) ។

១.២-ការប្រាក់ក្នុងអត្រា ៩,៧៥% (ប្រាំបួនក្បៀសចិតសិបប្រាំ) ភាគរយក្នុងមួយឆ្នាំ



Scanned with CamScanner

លើប្រាក់ដើមនៅជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) ដោយគិតចាប់ពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ។

១.៣-ការប្រាក់ពិន័យករណីបំពានលក្ខខណ្ឌអត្រា ១៨% (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) ដោយគិតចាប់ពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃបានសងគ្រប់ចំនួន ។

១.៤-ប្រាក់ពិន័យសម្រាប់ការ ទូទាត់យឺតយ៉ាវស្មើនឹងអត្រា ២៧% (ម្ភៃប្រាំពីរ) ភាគរយក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវ ទូទាត់សង ដោយគិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការ ទូទាត់សងគ្រប់ចំនួន ។

១.៥-ប្រាក់សំណងនៃការខូចខាត (សំណងជំងឺចិត្ត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ និងសេវាកម្មច្បាប់) ដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចចំនួន USD USD ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ។

១.៦-ប្រកាសសាលក្រមមានអានុភាពអនុវត្តបណ្តោះអាសន្នត្រង់ចំនុច ១.១, ១.២, ១.៣ និង ចំនុច ១.៤ ។

១.៧-ប្រាក់ប្រដាប់ក្តី និង ការចំណាយក្នុងរឿងក្តីជាបន្ទុករបស់សហចុងចម្លើយ ។

ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី:

កាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ [redacted] វុត្ថា និង ឈ្មោះ [redacted] ស៊ីវឡេង បានរួមគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគពីដើមចោទជា [redacted] ម.ក នូវប្រាក់ដើមចំនួន ៣០០.០០០ (បីរយពាន់ដុល្លារអាមេរិក) ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ និង កិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២ ។ សហចុងចម្លើយ ត្រូវរួមគ្នាសងមកឱ្យដើមចោទវិញដោយបង់រំលោះទាំងប្រាក់ដើម និង ការប្រាក់ក្នុងរយៈពេលខ្ចី ១២០ (មួយរយម្ភៃ) ខែ គិតចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០៣២ ក្នុងអត្រាការប្រាក់ ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយក្នុងមួយឆ្នាំ ហើយការប្រាក់នេះនឹងត្រូវតម្លើងរហូតដល់អត្រា ១៨% (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំ ប្រសិនបើខកខានសងលើសពី ៣ (បី) ខែ និងត្រូវពិន័យចំពោះការបង់យឺតយ៉ាវស្មើនឹងអត្រា ២៧% (ម្ភៃប្រាំពីរ) ភាគរយក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវ ទូទាត់សង ដោយគិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការ ទូទាត់សងគ្រប់ចំនួន ។ ក្រោយមកដើមចោទ [redacted] ម.ក បានធ្វើការជូនដំណឹងស្តីពីការតម្លើងការប្រាក់ពី ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយក្នុងមួយឆ្នាំ ទៅអត្រាការប្រាក់ ៩,៧៥% (ប្រាំបួនក្បៀសចិតសិបប្រាំ) ភាគរយក្នុងមួយឆ្នាំ ដល់សហចុងចម្លើយឈ្មោះ [redacted] វុត្ថា និង ឈ្មោះ [redacted] ស៊ីវឡេង ដោយផ្អែកតាមលិខិតជូនដំណឹងរបស់ដើមចោទ [redacted] ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៣ ។ ចំពោះការខ្ចីប្រាក់ខាងលើនេះ សហចុងចម្លើយបានរួមគ្នាបង្កើតហ៊ីប៉ូតែកចំពោះអចលនវត្ថុចំនួន ០២ ទីតាំង



Scanned with CamScanner

ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ៖ ២១០៨០២០៨-០១៨២ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ លេខ៖ ២១០៨០២០៨-០០៨២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ដើម្បីធានាលើបំណុលរបស់ខ្លួនផងដែរ ។

គ.សេចក្តីថ្លែងការណ៍របស់ភាគី:

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា: កាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ [redacted]វុត្ថា និង ឈ្មោះ [redacted]ស៊ីវឡេង បានរួមគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគពីដើមចោទជា [redacted] ម.ក នូវប្រាក់ដើមចំនួន ៣០០.០០០ (បីរយពាន់ដុល្លារអាមេរិក) ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២ ។ សហចុងចម្លើយ ត្រូវរួមគ្នាសងមកឱ្យដើមចោទវិញដោយបង់រំលោះទាំងប្រាក់ដើម និង ការប្រាក់ក្នុងរយៈពេលខ្ចី ១២០ (មួយរយម្ភៃ) ខែ គិតចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០៣២ ក្នុងអត្រាការប្រាក់ ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយ ក្នុងមួយឆ្នាំ ហើយការប្រាក់នេះនឹងត្រូវតម្លើងរហូតដល់អត្រា ១៨% (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំ ប្រសិនបើខកខានសងលើសពី ៣ (បី) ខែ និង ត្រូវពិន័យចំពោះការបង់យឺតយ៉ាវស្មើនឹងអត្រា ២៧% (ម្ភៃប្រាំពីរ) ភាគរយក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវ ទូរទាត់សង ដោយគិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការ ទូរទាត់សងគ្រប់ចំនួន ។ ក្រោយមកដើមចោទ [redacted] ម.ក បានធ្វើការជូនដំណឹងស្តីពីការតម្លើងការប្រាក់ពី ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយក្នុងមួយឆ្នាំ ទៅអត្រាការប្រាក់ ៩,៧៥% (ប្រាំបួនក្បៀសចិតសិបប្រាំ) ភាគរយក្នុងមួយឆ្នាំ ដល់សហចុងចម្លើយ ឈ្មោះ [redacted]វុត្ថា និង ឈ្មោះ [redacted]ស៊ីវឡេង ដោយផ្អែកតាមលិខិតជូនដំណឹងរបស់ដើមចោទ [redacted] ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៣ ។ ចំពោះការខ្ចីប្រាក់ខាងលើនេះ សហចុងចម្លើយបានរួមគ្នាបង្កើតហ៊ីប៉ូតែកចំពោះអចលនវត្ថុចំនួន ០២ ទីតាំង ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ៖ ២១០៨០២០៨-០១៨២ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ លេខ៖ ២១០៨០២០៨-០០៨២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ដើម្បីធានាលើបំណុលរបស់ខ្លួនផងដែរ ។

បន្ទាប់ពីទទួលបានប្រាក់កម្ចីរួចហើយ សហចុងចម្លើយបានទូរទាត់សងមកឱ្យដើមចោទវិញបានត្រឹមតែចំនួន ១០ (ដប់) លើកតែប៉ុណ្ណោះ គិតត្រឹមថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ ដែលសរុបជាទឹកប្រាក់ចំនួន ៤១.១៥៤,១១ ដុល្លារអាមេរិក ក្នុងនោះរួមមានប្រាក់ដើមចំនួន ១៧.១៤៧,១៤ ដុល្លារអាមេរិក និងការប្រាក់ចំនួន ២៤.០០៦,៩៧ ដុល្លារអាមេរិក ហើយបន្ទាប់មកសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមកាលកំណត់ឡើយ និង បានខកខានរហូតដល់បច្ចុប្បន្ននេះ ។ ក្នុងនាមខ្ញុំបាទ ជាអ្នកតំណាងស្របច្បាប់ឱ្យដើមចោទ [redacted] ម.ក នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖ ៦២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តតាកែវ ។ ខ្ញុំបាទសូមធ្វើសេចក្តីបញ្ជាក់អំពីមូលហេតុនៃការទាមទារ ចំពោះចំណុចនៃទាមទារនីមួយៗដូចខាងក្រោម៖



Scanned with CamScanner

១. មូលហេតុនៃការទាមទារចំនុច ១.១៖ ប្រាក់ដើមនៅជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន ) ដោយហេតុថា ឈ្មោះ [redacted]វុត្ថា និង ឈ្មោះ [redacted]ស៊ីវឡេង បានរួមគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគពីដើមចោទជា [redacted] ម.ក នូវប្រាក់ដើមចំនួន ៣០០.០០០ (បីរយពាន់ដុល្លារអាមេរិក) ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ។ ការខ្ចីប្រាក់នេះ ត្រូវបានការកំណត់អំពីប្រាក់ដើម ការប្រាក់ និង ប្រាក់ពិន័យក្នុងករណីមិនអនុវត្តកាតព្វកិច្ចយ៉ាងច្បាស់លាស់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ហើយក្នុងអំឡុងពេលអនុវត្តកិច្ចសន្យានោះ សហចុងចម្លើយបានរំលោភបំពានកាតព្វកិច្ចរបស់ខ្លួនមិនបានសងប្រាក់ (ប្រាក់ដើម ការប្រាក់ និង ប្រាក់ពិន័យ) តាមការកំណត់នោះទេ ។ ចំពោះប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់គិតត្រឹមថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ គឺមានប្រាក់ដើមចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) ។

២.មូលហេតុនៃការទាមទារចំនុច ១.២៖ ការប្រាក់ក្នុងអត្រា ៩,៧៥% (ប្រាំបួនក្បៀសចិតសិបប្រាំ) ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន ) ដោយគិតចាប់ពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ។ តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ត្រង់ចំណុច ២ (លក្ខណៈនៃឥណទាន) សហចុងចម្លើយបានឯកភាពលើកម្រិតអត្រាការប្រាក់ចំនួន ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយក្នុងមួយឆ្នាំ ។ មួយវិញទៀត ចំពោះអត្រាការប្រាក់ប្រចាំឆ្នាំ ដូចមានរៀបរាប់ខាងលើនេះ ដើមចោទបានធ្វើការជូនដំណឹងស្តីពីការតម្លើងការប្រាក់ពី ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយក្នុងមួយឆ្នាំ ទៅអត្រាការប្រាក់ ៩,៧៥% (ប្រាំបួនក្បៀសចិតសិបប្រាំ) ភាគរយក្នុងមួយឆ្នាំ ដោយផ្អែកតាមលិខិតជូនដំណឹង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២៣ ។ ដូចច្នេះ សហចុងចម្លើយមានកាតព្វកិច្ចត្រូវបង់ការប្រាក់ប្រចាំខែ មកឱ្យដើមចោទជារៀងរាល់ខែ ហើយអំឡុងពេលអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីនោះ សហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចាប់តាំងពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ មកម្ល៉េះ ។ ដូច្នេះ សហចុងចម្លើយត្រូវ ទូទាត់ការប្រាក់ក្នុងអត្រា ៩,២៥% (ប្រាំបួនក្បៀសម្ភៃប្រាំ) ភាគរយក្នុងមួយឆ្នាំលើប្រាក់ដើមកំពុងជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) មកឱ្យដើមចោទ ដោយគិតចាប់ពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ។

៣.មូលហេតុនៃការទាមទារចំនុច ១.៣៖ ការប្រាក់ពិន័យករណីបំពានលក្ខខណ្ឌអត្រា ១៨% (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) ដោយគិតចាប់ពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០២៣។ រហូតដល់ថ្ងៃបានសងគ្រប់ចំនួន ។ ដោយហេតុថា ៖ តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ត្រង់ចំនុច ១០ (អត្រាការប្រាក់ពិន័យ) សហចុងចម្លើយ បានឯកភាពលើការតម្លើងអត្រាការប្រាក់រហូតដល់ ១៨% (ដប់ប្រាំបីភាគ



Scanned with CamScanner

រយ) ក្នុងមួយឆ្នាំ ក្នុងករណីដែលសហាចុងចម្លើយយឺតយ៉ាវក្នុងការ ទូរទាត់សងប្រាក់ ដែលដល់កំណត់ត្រូវសងចាប់ពី ០៣ (បី) ខែឡើងទៅ ដោយគិតចាប់ពីថ្ងៃកំណត់ត្រូវ ទូរទាត់សង ។ ករណីនេះ សហាចុងចម្លើយមិនបាន ទូរទាត់សងប្រាក់ ដែលដល់កំណត់ថ្ងៃត្រូវសងមកឱ្យដើមចោទលើសពី ០៣ (បី)ខែ គឺគិតចាប់ពីថ្ងៃ ១៧ ខែតុលា ឆ្នាំ២០២៣ មកម្ល៉េះ ។ ដូច្នេះសហាចុងចម្លើយត្រូវមានកាតព្វកិច្ច ទូរទាត់សងនូវការប្រាក់ពិន័យ ករណីបំពានលក្ខខណ្ឌក្នុងអត្រា **១៨% (ដប់ប្រាំបីភាគរយ)** ក្នុងមួយឆ្នាំលើប្រាក់ដើមនៅជំពាក់ចំនួន **USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន)** ដោយគិតចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃបានសងគ្រប់ចំនួន ។

៤.**មូលហេតុនៃការទាមទារចំនុច ១.៤៖** ទាមទារប្រាក់ពិន័យសម្រាប់ការ ទូរទាត់យឺតយ៉ាវស្មើនឹងអត្រា **២៧% (ម្ភៃប្រាំពីរ)** ភាគរយក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវ ទូរទាត់សង ដោយគិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការ ទូរទាត់សងគ្រប់ចំនួន ។ដោយហេតុថា៖ នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ **ត្រង់ចំណុច ៣ (ការសងប្រាក់)** សហាចុងចម្លើយបានឯកភាពលើការបង់ប្រាក់យឺតយ៉ាវនឹងត្រូវពិន័យក្នុងអត្រា **២៧% (ម្ភៃប្រាំពីរភាគរយ)** ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវ ទូរទាត់សង គិតចាប់ពីពេលដល់កំណត់សងរហូតដល់ពេល ដែលទទួលបានការ ទូរទាត់គ្រប់ចំនួន ដោយគិតចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣ មកសហាចុងចម្លើយមិនបានបង់ប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យនោះទេ ។ ដូច្នេះ សហាចុងចម្លើយមានកាតព្វកិច្ច ទូរទាត់បង់ប្រាក់ពិន័យស្មើនឹង **២៧% (ម្ភៃប្រាំពីរភាគរយ)** ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវ ទូរទាត់សង ដោយគិតចាប់ពីពេលដល់កំណត់ត្រូវសង គឺថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ រហូតដល់ពេលទទួលបានការ ទូរទាត់គ្រប់ចំនួនមកឱ្យដើម ។

៥.**មូលហេតុនៃការទាមទារចំនុច ១.៥៖** ប្រាក់សំណងនៃការខូចខាត (សំណងជំងឺចិត្ត ការខាត់បង់ពេលវេលា ការចំណាយផ្សេងៗ និង សេវាកម្មច្បាប់) ដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចចំនួន USD ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ។ ដោយហេតុថា៖ ផ្អែកតាម ប្រការ៥ (ករណីបំពានលក្ខខណ្ឌ) ត្រង់ចំនុច ៥.២ (គ) (ដំណោះស្រាយក្នុងករណីបំពានលក្ខខណ្ឌ) ក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ បានបញ្ញាត្តិថា "**នៅពេលមានករណីបំពានលក្ខខណ្ឌកើតឡើង តាមឆន្ទានុសិទ្ធិរបស់ខ្លួន និងបន្ថែមលើសិទ្ធិផ្សេងទៀតដែលផ្តល់តាមរយៈឯកសារឥណទាន ធនាគារអាច ៖ នៅត្រង់ចំនុច (គ) ទាមទារឱ្យអ្នកខ្ចីបង់កម្រៃសេវា ការចំណាយ និងសោហ៊ុយ រាប់បញ្ចូលទាំងកម្រៃសេវាផ្នែកច្បាប់ដែលចំណាយដោយ ឬក្នុងនាមធនាគារ ដោយសារការកើតឡើងនៃករណីបំពានលក្ខខណ្ឌ ។**" បន្ថែមពីនេះ **វាក្យខណ្ឌទី១ នៃកថាខណ្ឌទី១ ក្នុងមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមរដ្ឋប្បវេណី** បានចែងថា "**១. ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន**" ។ ក្នុងរឿងនេះ សហាចុងចម្លើយមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របតាមកិច្ចសន្យាខ្ចីបរិភោគដែលមានយោង



Scanned with CamScanner

ខាងលើ ជាហេតុបណ្តាលឱ្យធនាគារខាតបង់ប្រយោជន៍ជាច្រើន រួមមានការខាតបង់ពេលវេលា និង ការចំណាយផ្សេងៗទៅលើការពិគ្រោះយោបល់ផ្នែកច្បាប់ជាមួយមេធាវី ដើម្បីដាក់ពាក្យបណ្តឹងទាមទារប្រាក់ពីសហចុងចម្លើយទៅតាមនីតិវិធីច្បាប់ ។ ដូច្នេះសហចុងចម្លើយមានកាតព្វកិច្ចសងសំណងខូចខាត មកឱ្យដើមចោទចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។

៦.មូលហេតុនៃការទាមទារចំនុច ១.៦ ៖ សុំឱ្យតុលាការប្រកាសសាលក្រមមានអានុភាពអនុវត្តជាបណ្តោះអាសន្នត្រង់ចំនុច១. (ប្រាក់ដើម), ចំនុច ២. (ការប្រាក់), ៣. (ការប្រាក់ពិន័យករណីបំពានលក្ខខណ្ឌ) និងចំនុច ៤. (ប្រាក់ពិន័យ) ។ ដោយហេតុថា៖ ដើមចោទមានភស្តុតាងច្បាស់លាស់ ដែលអាចឱ្យតុលាការធ្វើការសម្រេចប្រកាសសាលក្រមមានអានុភាពអនុវត្តបណ្តោះអាសន្នបាន ។ ដោយការខ្ចីប្រាក់នេះ មានការដាក់ធានាបំណុលតាមរយៈការបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ ត្រឹមត្រូវតាមនីតិវិធីច្បាប់ដែលការណ៍នេះ អាចអនុញ្ញាតឱ្យភាគីដើមចោទធ្វើការអនុវត្តដោយបង្ខំ ដើម្បីរឹបអូសទ្រព្យសម្បត្តិដែលបានបង្កើតហ៊ីប៉ូតែកនោះ ធ្វើការលក់ឡាយឡុងយកប្រាក់មកសងធនាគារ និងដើម្បីចៀសវាងហានិភ័យរបស់ធនាគារផងដែរ ដោយហេតុថា ធនាគាររីង គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលតែងតែមានតម្រូវការប្រាក់ ដើម្បីធ្វើការផ្តល់ប្រាក់កម្ចីជូនអតិថិជនជាច្រើនផ្សេងទៀត ។

៧.មូលហេតុនៃការទាមទារចំនុច ១.៧៖ ទាមទារឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី និងចំណាយផ្សេងៗក្នុងរឿងក្តី ។ ដោយហេតុថា៖ សហចុងចម្លើយ បានបំពានលក្ខខណ្ឌនៃកិច្ចសន្យា ហើយដើមចោទបានធ្វើការចរចាសម្របសម្រួលក្រៅប្រព័ន្ធតុលាការតាមរយៈការជូនដំណឹង ការជួបដោះស្រាយជាច្រើនលើក ប៉ុន្តែសហចុងចម្លើយបានត្រឹមតែសន្យា និង គេចវេះមិនបានអនុវត្តតាមការសន្យានោះទេ ដែលជាហេតុធ្វើឱ្យដើមចោទ ត្រូវធ្វើការដាក់ពាក្យបណ្តឹងទាមទារប្រាក់មកតុលាការ និងចំណាយទៅលើការបង់ពន្ធផ្សេងៗតាមនីតិវិធី ។

-សហចុងចម្លើយឈ្មោះ [redacted] វុត្ថា និង ប្រពន្ធឈ្មោះ [redacted] ស៊ីវឡេង បានធ្វើសេចក្តីថ្លែងការណ៍ថា: ចំពោះអត្រាការប្រាក់ចំនួន ៩.៧៥% ភាគរយក្នុងមួយឆ្នាំលើប្រាក់ដើម យើងខ្ញុំមិនទទួលស្គាល់ទេ តែយើងខ្ញុំសូមទទួលស្គាល់ការប្រាក់ក្នុងអត្រា ៩,២៥ % ក្នុងមួយឆ្នាំ លើប្រាក់ដើមដូចមានក្នុងកិច្ចសន្យាខ្ចីបរិភោគ ។ ការទាមទារប្រាក់ពិន័យបំពានលក្ខខណ្ឌក្នុងអត្រា ១៨% ភាគរយក្នុងមួយឆ្នាំលើប្រាក់ដើម យើងខ្ញុំសូមបដិសេធ ។ ការពិន័យលើការយឺតយ៉ាវដែលស្មើនឹង ២៧% ក្នុងមួយឆ្នាំលើប្រាក់ដើម យើងខ្ញុំសុំបដិសេធ ។ ការទាមទារប្រាក់សំណងជំងឺចិត្ត ការខាតបង់ពេលវេលា និង ការចំណាយផ្សេងៗចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក យើងខ្ញុំសូមបដិសេធ ។ យើងខ្ញុំសូមបដិសេធចំពោះការស្នើសុំឱ្យតុលាការប្រកាសសាលក្រមឱ្យអនុវត្តជាបណ្តោះអាសន្ន ។ យើងខ្ញុំពុំមានលទ្ធភាពបង់ប្រាក់ប្រដាប់ក្តីតាមការទាមទាររបស់ដើមចោទនោះទេ ។ យើងខ្ញុំសូមទទួលស្គាល់ថា នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគពីធនាគាររីង ដែលជាភាគីដើមចោទប្រាកដ

មែនដោយយើងខ្ញុំទទួលបានប្រាក់ជាក់ស្តែង នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២២ ។ នៅពេលដែលខ្ចីប្រាក់ពី[redacted] យើងខ្ញុំបានដាក់ទ្រព្យធានាចំនួន ០២ កន្លែង ក្នុងទឹកប្រាក់ចំនួន ៣០០.០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក ក្រោយពីបានទទួលប្រាក់រួចហើយ យើងខ្ញុំបានអនុវត្តកាតព្វកិច្ចបានចំនួន ១១ (ដប់មួយ) ខែ ។ បន្ទាប់មកការរកស៊ី មិនបានកាក់កបទៅមុខដោយរលូនទេ បូកផ្សំនឹងវិបត្តិសេដ្ឋកិច្ច ហើយត្រូវគេបោកទៀត និង មានគេអ្នកលេងតុងទីនយកយើងខ្ញុំទៅធានាលើបំណុល មានចំនួនទឹកប្រាក់ស្មើនឹង ១៧០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ហើយក៏មានគេទិញម៉ូតូពីយើងខ្ញុំអត់ឱ្យលុយ ចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លារអាមេរិក ទៀតផង ។ យើងខ្ញុំសូមស្នើសុំរយៈពេល ០៣ (បី) ឆ្នាំ បន្តទៅមុខទៀតដើម្បីឱ្យយើងខ្ញុំបានដាក់លក់ទ្រព្យ ដើម្បីយកលុយសងឱ្យធនាគារវីង បើយើងខ្ញុំលក់បានស្តែកយើងខ្ញុំនឹងសងភ្លាមឱ្យបានគ្រប់ចំនួន ។ បច្ចុប្បន្ននេះ យើងខ្ញុំអាចសងឱ្យដើមចោទក្នុងមួយខែតែចំនួន ៥០ (ហាសិប) ដុល្លារអាមេរិកប៉ុណ្ណោះ រហូតដល់គ្រប់ចំនួន ។ យើងខ្ញុំយល់ព្រមឱ្យដើមចោទ កាត់យកដីយើងខ្ញុំចំនួន០៤ កន្លែងផ្សេងៗទៀត ក្រៅពីដីផ្ទះដែលយើងខ្ញុំកំពុងរស់នៅសព្វថ្ងៃ ដើម្បីកាត់កងលើបំណុល ។ យើងខ្ញុំសូមទទួលស្គាល់ថា នៅជំពាក់ប្រាក់ធនាគារវីងតែចំនួន ២៧៩.៣៩៩.៩៣ (ម្ភៃប្រាំពីរម៉ឺនប្រាំបួនពាន់បីរយកៅសិបប្រាំបួនដុល្លារ អាមេរិក និងកៅសិបបីសេន) ប៉ុណ្ណោះ លើសពីនេះយើងខ្ញុំមិនទទួលស្គាល់ទេ ។ កន្លងមកយើងខ្ញុំធ្លាប់បានស្នើសុំឱ្យខាង[redacted] ធ្វើបច្ចុប្បន្នភាពលើតារាងបង់ប្រាក់ដែរ តែខាងធនាគារមិនបានធ្វើឱ្យយើងខ្ញុំទេ ។

លោក [redacted] ហាប់ ជាអ្នកតំណាងឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា: ការលើកឡើងរបស់សហចុងចម្លើយដែលថា សុំកាត់កងដីចំនួន ០៤ កន្លែង ដើម្បីទូរទាត់បំណុល, ការស្នើសុំរយៈពេល ០៣ ឆ្នាំទៅមុខបន្តទៀត និង ការស្នើសុំបង់ក្នុងមួយខែចំនួន ៥០ ដុល្លារអាមេរិក គឺខាង[redacted]មិនអាចទទួលយកបានទេ ដោយសារតែធាគារវីង ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត និងដែលត្រូវការជាចាំបាច់នូវសាច់ប្រាក់ ដើម្បីបម្រើសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុដល់អតិថិជនផ្សេងទៀត ។ ដូចនេះហើយ ក្នុងនាមខ្ញុំបាទជាអ្នកតំណាងឱ្យដើមចោទ សូមស្នើសុំឱ្យតុលាការចេញសាលក្រមសម្រេច ទៅតាមការទាមទារដូចមាននៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹង ។

**ឃ.ចំណុចវិវាទ និង គ្មានវិវាទនៃរឿងក្តី:**

+ចំណុចវិវាទ:

-ប្រាក់ដើមមានចំនួនខុសគ្នា

-ការប្រាក់គិតលំអៀងខុសគ្នា

-ប្រាក់ពិន័យបំពានលក្ខខណ្ឌក្នុងមួយឆ្នាំ ១៨% មិនឯកភាពគ្នា

-ប្រាក់ពិន័យទូរទាត់យឺតយ៉ាវ ក្នុងមួយឆ្នាំ ២៧% មិនឯកភាពគ្នា

-សំណងការខូចខាតពេលវេលា សំណងជំងឺចិត្តសហចុងចម្លើយមិនមានលទ្ធភាព

-ការស្នើសុំឱ្យអនុវត្តជាបណ្តោះអាសន្ន ក៏សហចុងចម្លើយក៏មិនឯកភាព

-សហចុងចម្លើយមិនមានលទ្ធភាព បង់ប្រាក់ប្រដាប់ក្តីត្រឡប់ឱ្យវិញទេ ។



Scanned with CamScanner

ខាងលើ ជាហេតុបណ្ដាលឱ្យធនាគារខាតបង់ប្រយោជន៍ជាច្រើន រួមមានការខាតបង់ពេលវេលា និង ការចំណាយផ្សេងៗទៅលើការពិគ្រោះយោបល់ផ្នែកច្បាប់ជាមួយមេធាវី ដើម្បីដាក់ពាក្យបណ្ដឹងទាមទារប្រាក់ពីសហចុងចម្លើយទៅតាមនីតិវិធីច្បាប់ ។ ដូច្នេះសហចុងចម្លើយមានកាតព្វកិច្ចសងសំណងខូចខាត មកឱ្យដើមចោទចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។

៦.<u>មូលហេតុនៃការទាមទារចំនុច ១.៦</u> ៖ សុំឱ្យតុលាការប្រកាសសាលក្រមមានអានុភាពអនុវត្តជាបណ្ដោះអាសន្នត្រង់ចំនុច១. (ប្រាក់ដើម), ចំនុច ២. (ការប្រាក់), ៣. (ការប្រាក់ពិន័យករណីបំពានលក្ខខណ្ឌ) និងចំនុច ៤. (ប្រាក់ពិន័យ) ។ ដោយហេតុថា៖ ដើមចោទមានភស្តុតាងច្បាស់លាស់ ដែលអាចឱ្យតុលាការធ្វើការសម្រេចប្រកាសសាលក្រមមានអានុភាពអនុវត្តបណ្ដោះអាសន្នបាន ។ ដោយការខ្ចីប្រាក់នេះ មានការដាក់ធានាបំណុលតាមរយៈការបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ ត្រឹមត្រូវតាមនីតិវិធីច្បាប់ដែលករណីនេះ អាចអនុញ្ញាតឱ្យភាគីដើមចោទធ្វើការអនុវត្តដោយបង្ខំ ដើម្បីរឹបអូសទ្រព្យសម្បត្តិដែលបានបង្កើតហ៊ីប៉ូតែកនោះ ធ្វើការលក់ឡាយឡុងយកប្រាក់មកសងធនាគារ និងដើម្បីចៀសវាងហានិភ័យរបស់ធនាគារផងដែរ ដោយហេតុថា ធនាគាររីង គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលតែងតែមានតម្រូវការប្រាក់ ដើម្បីធ្វើការផ្ដល់ប្រាក់កម្ចីជូនអតិថិជនជាច្រើនផ្សេងទៀត ។

៧.<u>មូលហេតុនៃការទាមទារចំនុច ១.៧</u>៖ ទាមទារឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី និងចំណាយផ្សេងៗក្នុងរឿងក្ដី ។ ដោយហេតុថា៖ សហចុងចម្លើយ បានបំពានលក្ខខណ្ឌនៃកិច្ចសន្យា ហើយដើមចោទបានធ្វើការចរចាសម្របសម្រួលក្រៅប្រព័ន្ធតុលាការតាមរយៈការជូនដំណឹង ការជួបដោះស្រាយជាច្រើនលើក ប៉ុន្តែសហចុងចម្លើយបានត្រឹមតែសន្យា និង គេចវេះមិនបានអនុវត្តតាមការសន្យានោះទេ ដែលជាហេតុធ្វើឱ្យដើមចោទ ត្រូវធ្វើការដាក់ពាក្យបណ្ដឹងទាមទារប្រាក់មកតុលាការ និងចំណាយទៅលើការបង់ពន្ធផ្សេងៗតាមនីតិវិធី ។

-សហចុងចម្លើយឈ្មោះ [redacted] វុត្ថា និង ប្រពន្ធឈ្មោះ [redacted] ស៊ីវឡេង បានធ្វើសេចក្ដីថ្លែងការណ៍ថា: ចំពោះអត្រាការប្រាក់ចំនួន ៩.៧៥% ភាគរយក្នុងមួយឆ្នាំលើប្រាក់ដើម យើងខ្ញុំមិនទទួលស្គាល់ទេ តែយើងខ្ញុំសូមទទួលស្គាល់ការប្រាក់ក្នុងអត្រា ៩,២៥ % ក្នុងមួយឆ្នាំ លើប្រាក់ដើមដូចមានក្នុងកិច្ចសន្យាខ្ចីបរិភោគ ។ ការទាមទារប្រាក់ពិន័យបំពានលក្ខខណ្ឌក្នុងអត្រា ១៨% ភាគរយក្នុងមួយឆ្នាំលើប្រាក់ដើម យើងខ្ញុំសូមបដិសេធ ។ ការពិន័យលើការយឺតយ៉ាវដែលស្មើនឹង ២៧% ក្នុងមួយឆ្នាំលើប្រាក់ដើម យើងខ្ញុំសុំបដិសេធ ។ ការទាមទារប្រាក់សំណងជំងឺចិត្ត ការខាតបង់ពេលវេលា និង ការចំណាយផ្សេងៗចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក យើងខ្ញុំសូមបដិសេធ ។ យើងខ្ញុំសូមបដិសេធចំពោះការស្នើសុំឱ្យតុលាការប្រកាសសាលក្រមឱ្យអនុវត្តជាបណ្ដោះអាសន្ន ។ យើងខ្ញុំពុំមានលទ្ធភាពបង់ប្រាក់ប្រដាប់ក្ដីតាមការទាមទាររបស់ដើមចោទនោះទេ ។ យើងខ្ញុំសូមទទួលស្គាល់ថា នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគពីធនាគាររីង ដែលជាភាគីដើមចោទប្រាកដ



Scanned with CamScanner

មែនដោយយើងខ្ញុំទទួលបានប្រាក់ជាក់ស្តែង នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២២ ។ នៅពេលដែលខ្ចីប្រាក់ពីធនាគាររីង យើងខ្ញុំបានដាក់ទ្រព្យធានាចំនួន ០២ កន្លែង ក្នុងទឹកប្រាក់ចំនួន ៣០០.០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក ក្រោយពីបានទទួលប្រាក់រួចហើយ យើងខ្ញុំបានអនុវត្តកាតព្វកិច្ចបានចំនួន ១១ (ដប់មួយ) ខែ ។ បន្ទាប់មកការរកស៊ី មិនបានកាក់កបទៅមុខដោយរលូនទេ បូកផ្សំនឹងវិបត្តិសេដ្ឋកិច្ច ហើយត្រូវគេបោកទៀត និង មានគេអ្នកលេងគុងទីនយកយើងខ្ញុំទៅធានាលើបំណុល មានចំនួនទឹកប្រាក់ស្មើនឹង ១៧០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ហើយក៏មានគេទិញម៉ូតូពីយើងខ្ញុំអត់ឱ្យលុយ ចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លារអាមេរិក ទៀតផង ។ យើងខ្ញុំសូមស្នើសុំរយៈពេល ០៣ (បី) ឆ្នាំ បន្តទៅមុខទៀត ដើម្បីឱ្យយើងខ្ញុំបានដាក់លក់ទ្រព្យ ដើម្បីយកលុយសងឱ្យធនាគាររីង បើយើងខ្ញុំលក់បានស្អែក យើងខ្ញុំនឹងសងភ្លាមឱ្យបានគ្រប់ចំនួន ។ បច្ចុប្បន្ននេះ យើងខ្ញុំអាចសងឱ្យដើមចោទក្នុងមួយខែតែចំនួន ៥០ (ហាសិប) ដុល្លារអាមេរិកប៉ុណ្ណោះ រហូតដល់គ្រប់ចំនួន ។ យើងខ្ញុំយល់ព្រមឱ្យដើមចោទ កាត់យកដីយើងខ្ញុំចំនួន០៤ កន្លែងផ្សេងៗទៀត ក្រៅពីដីផ្ទះដែលយើងខ្ញុំកំពុងរស់នៅសព្វថ្ងៃ ដើម្បីកាត់កងលើបំណុល ។ យើងខ្ញុំសូមទទួលស្គាល់ថា នៅជំពាក់ប្រាក់ធនាគាររីងតែចំនួន ២៧៩.៣៩៩.៩៣ (ម្ភៃប្រាំពីរម៉ឺនប្រាំបួនពាន់បីរយកៅសិបប្រាំបួនដុល្លារ អាមេរិក និងកៅសិបបីសេន) ប៉ុណ្ណោះ លើសពីនេះយើងខ្ញុំមិនទទួលស្គាល់ទេ ។ កន្លងមកយើងខ្ញុំធ្លាប់បានស្នើសុំឱ្យខាងធនាគាររីង ធ្វើបច្ចុប្បន្នភាពលើតារាងបង់ប្រាក់ដែរ តែខាងធនាគារមិនបានធ្វើឱ្យយើងខ្ញុំទេ ។

លោក [redacted] ហាប់ ជាអ្នកតំណាងឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា: ការលើកឡើងរបស់សហចុងចម្លើយដែលថា សុំកាត់កងដីចំនួន ០៤ កន្លែង ដើម្បីទូទាត់បំណុល, ការស្នើសុំរយៈពេល ០៣ ឆ្នាំទៅមុខបន្តទៀត និង ការស្នើសុំបង់ក្នុងមួយខែចំនួន ៥០ ដុល្លារអាមេរិក គឺខាងធនគាររីង មិនអាចទទួលយកបានទេ ដោយសារតែធាគាររីង ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត និងដែលត្រូវការជាចាំបាច់នូវសាច់ប្រាក់ ដើម្បីបម្រើសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុដល់អតិថិជនផ្សេងទៀត ។ ដូចនេះហើយ ក្នុងនាមខ្ញុំបាទជាអ្នកតំណាងឱ្យដើមចោទ សូមស្នើសុំឱ្យតុលាការចេញសាលក្រមសម្រេច ទៅតាមការទាមទារដូចមាននៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹង ។

**ឃ.ចំណុចវិវាទ និង គ្មានវិវាទនៃរឿងក្តី:**

+ចំណុចវិវាទ:

-ប្រាក់ដើមមានចំនួនខុសគ្នា

-ការប្រាក់គិតលំអៀងខុសគ្នា

-ប្រាក់ពិន័យបំពានលក្ខខណ្ឌក្នុងមួយឆ្នាំ ១៨% មិនឯកភាពគ្នា

-ប្រាក់ពិន័យទូទាត់យឺតយ៉ាវ ក្នុងមួយឆ្នាំ ២៧% មិនឯកភាពគ្នា

-សំណងការខូចខាតពេលវេលា សំណងជំងឺចិត្តសហចុងចម្លើយមិនមានលទ្ធភាព

-ការស្នើសុំឱ្យអនុវត្តជាបណ្តោះអាសន្ន ក៏សហចុងចម្លើយក៏មិនឯកភាព

-សហចុងចម្លើយមិនមានលទ្ធភាព បង់ប្រាក់ប្រដាប់ក្តីត្រឡប់ឱ្យវិញទេ ។



Scanned with CamScanner

+ចំណុចគ្មានវិវាទនៃរឿងក្តីៈ គ្មាន ។

## ឯកសារដែលជាភស្តុតាងៈ

១-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ ដែលធ្វើឡើងរវាងដើមចោទ និង សហចុងចម្លើយ ។

២-កិច្ចសន្យាបង្កើតហ៊ុប៉ូតែករួម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ដែលធ្វើរវាងដើមចោទ និង សហចុងចម្លើយ ។

៣-តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២ ដែលធ្វើរវាងដើមចោទ និង សហចុងចម្លើយ ។

៤-លិខិតជូនដំណឹង ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៣ ដែលធ្វើឡើងដោយដើមចោទ ។

៥-លិខិតជូនដំណឹងលើកទី ១ លេខៈ ០៧៣/២០២៣ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២៣ ដែលធ្វើឡើងដោយដើមចោទ ។

៦-លិខិតជូនដំណឹងលើកទី ២ លេខៈ ០៣៨/២០២៣ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២៣ ដែលធ្វើឡើងដោយដើមចោទ ។

៧-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ:១០០៧៧១៩៨២ របស់ឈ្មោះ [redacted] វុត្ថា ។

៨-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខៈ ១០០៧៧១៩៨០ របស់ឈ្មោះ [redacted] ស៊ីវឡេង ។

៩-វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៨០២០៨-០១៨២ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ ។

១០-វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៨០២០៨-០០៨២ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និង ការពិនិត្យភស្តុតាងនានានៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក ឃើញថា:

-ពាក្យបណ្តឹង ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ដើមចោទ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-ការទាមទាររបស់អ្នកតំណាងឱ្យដើមចោទ ពីសហចុងចម្លើយលើប្រាក់ដើមចំនួន USD **២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន)** ដែលពុំទាន់បានទូទាត់សង ឃើញថា ការទាមទារនូវចំនួនទឹកប្រាក់នេះ មានភាពដូចគ្នាទៅនឹងតារាងសាច់ប្រាក់ ដែលភាគីបានព្រមព្រៀងគ្នានៅចំនួនទឹកប្រាក់ចុងក្រោយ។ ហេតុដូច្នេះ គប្បីតុលាការពិចារណា និង សម្រេច ។

-ការអះអាងរបស់សហចុងចម្លើយដែលថាៈ ចំនួនទឹកប្រាក់ដែលពួកខ្លួននៅជំពាក់ គឺនៅប្រហាក់ប្រហែលគ្នាទៅនឹងចំនួនទឹកប្រាក់ ដែលដើមចោទបានប្តឹងទាមទារ ។ គប្បីតុលាការពិចារណា និង សម្រេច ។

-ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២២ អាចបញ្ជាក់បានថា សហចុងចម្លើយ ពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគពីដើមចោទប្រាកដមែន ។ ហេតុដូចនេះ



Scanned with CamScanner

ដើមចោទមានសិទ្ធិពេញលេញ ក្នុងការទាមទារឱ្យសហចុងចម្លើយ អនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយផ្អែកតាមបញ្ញត្តិមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី ។

-ផ្អែកតាមវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៨០២០៨-០១៨២ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ និង វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៨០២០៨-០០៨២ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ ឃើញថា សហចុងចម្លើយ ពិតជាបានបង្កើតកិច្ចសន្យាហ៊ីប៉ូតែកជាមួយនឹងដើមចោទ ប្រាកដមែន ។

-ចំពោះការបដិសេធរបស់សហចុងចម្លើយ លើអត្រាការប្រាក់ចំនួន ៩.៧៥% ភាគរយក្នុងមួយឆ្នាំលើប្រាក់ដើម គប្បីតុលាការពិចារណា និង សម្រេច ។

-ការទទួលស្គាល់របស់សហចុងចម្លើយ លើការប្រាក់ក្នុងអត្រា ៩,២៥% ក្នុងមួយឆ្នាំលើប្រាក់ដើម គប្បីតុលាការពិចារណា និង សម្រេច ។

-ការទាមទាររបស់អ្នកតំណាងឱ្យដើមចោទ លើប្រាក់ពិន័យក្នុងករណីបំពានលក្ខខណ្ឌ, ប្រាក់ពិន័យចំពោះការយឺតយ៉ាវ, និង ការដែលឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី គប្បីតុលាការពិចារណា និង សម្រេចទៅតាមច្បាប់ ។

-ការទាមទារសំណងការខូចខាត (សំណងជំងឺចិត្ត, ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ និង សេវាកម្មផ្លូវច្បាប់) របស់អ្នកតំណាងឱ្យដើមចោទ គប្បីតុលាការពិចារណា តាមបញ្ញត្តិមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី ។

-ការស្នើសុំឱ្យតុលាការប្រកាសសាលក្រមអនុវត្តជាបណ្ដោះអាសន្ន របស់ភាគីដើមចោទ គប្បីតុលាការពិចារណាតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-ការបដិសេធរបស់សហចុងចម្លើយ លើប្រាក់ពិន័យក្នុងករណីបំពានលក្ខខណ្ឌ, ប្រាក់ពិន័យចំពោះការយឺតយ៉ាវ, សំណងជំងឺចិត្ត, ប្រាក់ប្រដាប់ក្ដី និងការស្នើសុំឱ្យប្រកាសសាលក្រមអនុវត្តជាបណ្ដោះអាសន្ន ផ្អែកតាមការទាមទាររបស់ដើមចោទ ។ គប្បីតុលាការពិចារណាតាមសមាមាត្រនៃព្យសនកម្មដែលដើមចោទអាចនឹងទទួលរង ។

-ប្រាក់ប្រដាប់ក្ដី ត្រូវពិនិត្យតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ហេតុដូច្នេះសម្រេច**

១.លើកចោលនូវការលើកឡើងទាមទាររបស់ដើមចោទ [redacted] នៅក្នុងពាក្យបណ្ដឹង ដែលសុំឱ្យអនុវត្តជាបណ្ដោះអាសន្ន ត្រង់ចំណុច ១.២, ១.៣ និង ១.៤ ។

២.បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន **USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន)** ឱ្យមកដើមចោទរហូតដល់គ្រប់ចំនួន ។

៣.បង្គាប់ឱ្យសហចុងចម្លើយ សងការប្រាក់គិតក្នុងអត្រា **៩,៧៥% (ប្រាំបួនក្បៀសចិតសិបប្រាំ)** ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន **USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន)** ដោយគិតចាប់ពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ។

៤.បង្គាប់ឱ្យសហចុងចម្លើយ សងប្រាក់ពិន័យគិតជាអត្រា ២៧% (ម្ភៃប្រាំពីរ) ភាគរយ



Scanned with CamScanner

ក្នុងមួយឆ្នាំនៃប្រាក់ដើមចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) ដោយគិតចាប់ពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

៥.បង្គាប់ឱ្យសហចុងចម្លើយ សងការខាតបង់ពេលវេលា សំណងជំងឺចិត្ត និង ចំណាយសេវាកម្មផ្លូវច្បាប់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ។ ការទាមទារលើសនេះត្រូវបដិសេធចោល ។

៦.ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់សហចុងចម្លើយ ។

៧.សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្ន ដែលទាមទារប្រាក់ដើមចំនួន USD ២៨២.៨៥២.៨៦ (ពីររយប៉ែតសិបពីរពាន់ប្រាំបីរយហាសិបពីរដុល្លារអាមេរិក ចុចប៉ែតសិបប្រាំមួយសេន) ។

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៤ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ចំពោះមុខអ្នកតំណាងស្របច្បាប់ឱ្យដើមចោទឈ្មោះ [redacted] ហាប់ និង ចំពោះមុខសហចុងចម្លើយឈ្មោះ [redacted] វុត្ថា និងប្រពន្ធឈ្មោះ [redacted] ស៊ីវឡេង ។

-ទុកសិទ្ធិឱ្យភាគីប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃសុក្រ ០៧ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
តាកែវ,ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និង ត្រា: [redacted]

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)
ថ្ងៃសុក្រ ០៧ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
តាកែវ,ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រម**

[redacted]



Scanned with CamScanner